ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧១៨ សហវ.ទស

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១១

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ:** ករណីសំណើសុំបុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ជួសជុលទំនប់ថ្នល់បត់ និងសាងសង់សំណង់បង្ហៀរលើទំនប់ ស្ថិតក្នុងឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- លិខិតលេខ ០២២ ធទឧ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមប្រតិភូជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឲ្យក្រសួងធនធានទឹកនិងឧតុនិយម បុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ចំនួន ១.៦០០.០០០.០០០ រៀល (មួយពាន់ប្រាំមួយរយលានរៀលគត់) ជូននាយកដ្ឋានវិស្វកម្ម នៃក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ជួសជុលទំនប់ថ្នល់បត់ និងសាងសង់សំណង់បង្ហៀរលើទំនប់ ស្ថិតក្នុងឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន មានដូចខាងក្រោម ៖

- ជួសជុលទំនប់ថ្នល់បត់ ប្រវែង ៤៣៦ ម៉ែត្រ
- សាងសង់សំណង់បង្ហៀរប្រវែង ៦៣,៥ម មានទ្វា០១លើទំនប់ ចំនួន ០១ កន្លែង

ខ្ទង់ប្រាក់បុរេប្រទាននេះ នឹងត្រូវទូទាត់ដោយឥណទានថវិការបស់ក្រសួងធនធានទឹកនិងឧតុនិយម ដោយអាណត្តិបើកប្រាក់ឲ្យបានទាន់ពេលវេលា ។

សូមឯកឧត្តមប្រតិភូមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ»
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាលាខេត្តប៉ៃលិន
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តប៉ៃលិន
- ឯកសារ-កាលប្បវត្តិ